# លទ្ធផលសង្ខេបអំពីកិច្ចសន្ទនាតុមូលស្តីពី
# ការបង្កើនកិច្ចការពារផ្នែកច្បាប់ដល់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា
# នៅប្រទេសកម្ពុជា កម្មវិធីសម្តែងនិងពិព័រណ៍សិល្បៈ
# ថ្ងៃទី៩ និង ទី១១ ខែធ្នូ ឆ្នាំ២០២១

វីដេអូសង្ខេបពីកម្មវិធី៖ https://www.youtube.com/watch?v=fXYQEpCVQEM



ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី៖ កិច្ចសន្ទនាតុមូលស្តីពីការបង្កើនកិច្ចការពារផ្នែកច្បាប់ដល់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា ក្រោមអធិបតីភាព ឯ.ឧ. កែវ រ៉េមី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (អ្នកចូលរួមសរុបចំនួន ៨៥នាក់)

ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

## ១. កំណត់បាននូវយន្តការមួយចំនួនក្នុងការស្វែងរកដោះស្រាយផ្នែកផ្លូវច្បាប់អាពាហ៍ពិពាហ៍ សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា ៖

១.១. សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានបង្ហាញការស្នើសុំជាថ្មីម្តងទៀតពីការ**បង្កើតក្រុមការងារចម្រុះ**ទទួលបន្ទុកលើកិច្ចការសិក្សានិងពិនិត្យទិដ្ឋភាពផ្នែកច្បាប់ នៃសមភាពអាពាហ៍ពិពាហ៍

១.២. សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានស្វែងយល់ច្បាស់លាស់ជាងមុនពីមុនអំពី **យន្តការរបស់ក្រសួងមហាផ្ទៃ** ដែលមានស្រាប់ ក្នុងការទទួលនិងពិនិត្យលើសេចក្តីព្រាងវិសោធនកម្មច្បាប់សម្រាប់ការចុះសំបុត្រអាពាហ៍ពិពាហ៍របស់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា

១.៣. ក្រសួងនិងស្ថាប័នជាតិរួមមាន ក្រសួងមហាផ្ទៃ កិច្ចការនារី គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលបាន **ពិភាក្សានិងសហការផ្ទាល់ជាមួយនឹងសហគមន៍យើង បង្កើនការយល់ដឹងអំពីបញ្ហាប្រឈមនិងសេចក្តីត្រូវការនៃ**ការការពារផ្នែកច្បាប់សម្រាប់ដៃគូ និងគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា ជាក់ស្តែងគឺអំពីតម្រូវការនិងសារៈសំខាន់នៃសំបុត្រអាពាហ៍ពិពាហ៍។ លទ្ធផលទាំងនេះទទួលបានតាមរយៈ ៖

## ១.៣.១. សេចក្តីស្នើសុំរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាទៅកាន់តំណាងរាជរដ្ឋាភិបាល អំពីតម្រូវការរបស់ខ្លួន បានបង្ហាញដោយមានលក្ខណៈដាក់លាក់ ច្បាស់លាស់ និងពិតប្រាកដ ព្រមទាំងមានការពន្យល់ហេតុផលយ៉ាងក្បោះក្បាយ និងពោរពេញដោយទំនុកចិត្ត។






ខ្ញុំទទួលយក

RUCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

១.៣.២. សេចក្តីស្នើសុំផ្តោតដាក់លាក់លើ “[សេចក្តីថ្លែងការណ៍រួម](#)របស់អង្គការសង្គមស៊ីវិលស្តីពី ការបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ) នៅក្នុងប្រទេសកម្ពុជា ឆ្លើយតបនឹងអនុសាសន៍នៃការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (UPR) ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក“ ដែលគាំទ្រដោយសង្គមស៊ីវិលចំនួន១៦ និងដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងក្រសួងកិច្ចការនារីនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១








### ១.៣.៣. សកម្មភាពនិងវិធីសាស្រ្តរវាងបណ្តាញអង្គការ និងរដ្ឋាភិបាលកម្ពុជា រដ្ឋផ្តល់អនុសាសន៍យូ.ភី.អ និងភ្នាក់ងារអង្គការសហប្រជាជាតិមានភាពច្បាស់លាស់ ជាប់លាប់ ជាប្រចាំ ខ្វះខ្វែង និងការផ្ញើសារនៃសេចក្តីត្រូវការ ដែលមានភាពទន់ភ្លន់ក្នុងការស្វែងរកដំណោះស្រាយ ជាជាងការបង្ខំ បន្ទច់បង្អាក់ ស្តីបន្ទោស និងកសាងទំនុកចិត្ត









ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

## ១.៣.៤. កំណើននៃសម្លេងគាំទ្រ ចំពោះសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗ រួមមានឪពុកម្តាយ អាជ្ញាធរមូលដ្ឋាន សារព័ត៌មាន អង្គការសង្គមស៊ីវិល សាធារណជន បុគ្គលដែលមានឥទ្ធិពលក្នុងសង្គម ( Influencers)











**២. អាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ/សង្កាត់) និងតំណាងរាជរដ្ឋាភិបាល បានចូលរួមគាំទ្រ នូវការសម្ពោធយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ**ទូទាំងប្រទេស ដើម្បីបង្កើនកិច្ចគាំពារនិងការទទួលយកអ្នកស្រឡាញ់ភេទដូចគ្នាក៏ដូចជាសារៈប្រយោជន៍នៃសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា។



## ៣. អាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ/សង្កាត់) បង្ហាញការគាំទ្រសម្រាប់ដៃគូភេទដូចគ្នា

អាជ្ញាធរមូលដ្ឋាន បានបង្ហាញពីការអនុវត្តជាក់ស្តែង ទាំងឆន្ទៈ ចំពោះការផ្តល់លិខិតអត្រានុកូលដ្ឋាន ឬ លិខិតស្នាមផ្សេងៗ និងអំពាវនាវដល់អាជ្ញាធរថ្នាក់ជាតិ ធ្វើការដោះស្រាយបញ្ហាផ្លូវច្បាប់ ដើម្បីអនុញ្ញាតឱ្យដៃគូអ្នកស្រឡាញ់ភេទដូចគ្នាអាចុះសំបុត្រអាពាហ៍ពិពាហ៍បាន








ខ្ញុំទទួលយក

RoCK
RAINBOW COMMUNITY KAMPUCHEA
ORGANISATION

## ៣.១. អាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ/សង្កាត់) ទទួលស្គាល់អំពីបញ្ហាប្រឈមនិងតម្រូវការរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសសេចក្តីព្យាយាម អំណត់អត់ធ្មត់ ក្នុងការចុះអប់រំផ្សព្វផ្សាយ កៀរគរ និងសហការរបស់ក្រុមការងាររ៉ក់កន្លងមកជាមួយអាជ្ញាធរមូលដ្ឋាន។



*ការគាំទ្ររបស់អាជ្ញាធរមូលដ្ឋានចំពោះដៃគូភេទដូចគ្នាកើតឡើងចេញពីការលើកកម្ពស់ការយល់ដឹងយ៉ាងសកម្មជាច្រើនឆ្នាំកន្លងមក ការទំនាក់ទំនងនិងសហការដោយចំហ និងគោរព។*

*អ្នកមីង មុន្នី បានលើកឡើងថា*

***«ខ្ញុំនៅមូលដ្ឋានឃើញផ្ទាល់ ជួបផ្ទាល់ និងធ្វើផ្ទាល់។ ខ្ញុំគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នារហូតមក និងជានិច្ច ប៉ុន្តែរដ្ឋាភិបាលថ្នាក់ជាតិត្រូវជួយដោះស្រាយរឿងបញ្ហាផ្លូវច្បាប់ទើបខ្ញុំអាចអនុវត្តន៍បាន ដើម្បីជួយដល់ពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្ញុំ។»***

ខ្ញុំទទួលយក

RUCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

## ៤. ឪពុកម្ដាយចូលរួមគាំទ្រកូននិងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដោយសកម្មនិងចំហ



ឪពុកម្ដាយចែករំលែកបទពិសោធន៍ និងការយល់ឃើញអំពីការទទួលយក និងការគាំទ្រដំណើរនៃកូនជាអ្នកស្រឡាញ់ភេទដូចគ្នា ។ នេះជាការផ្ដល់នូវភស្តុតាងពីការគាំទ្រដ៏រឹងមាំទៅកាន់រាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន សាធារណជន ហើយក៏ជាក្ដីសង្ឃឹមសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសយុវជន ។



ក្តីស្រឡាញ់ឥតលក្ខខណ្ឌរបស់ឪពុកម្តាយដែលយល់និងចង់ឃើញកូនមានសុភមង្គលដែលចូលរួមក្នុង ផ្តាល់ដែលចង់ឃើញកូនល្អ និងមើលឃើញពីតម្លៃនៃការគស៊ូមតិឱ្យមានច្បាប់អាពាហ៍ពិពាហ៍សម្រាប់កូនៗ តាមរយៈ សកម្មភាពបង្កើតកម្រងរូបថត ចូលរួមជាវាគ្មិននៅក្នុងកិច្ចសន្ទនាតុមូល សន្និសិទសារព័ត៌មាន ផ្តល់សម្ភាសន៍ក្នុងកម្មវិធីវិទ្យុ ទូរទស្សន៍ និងកាសែតជាដើម។

## ៤.១. ការខំប្រឹងប្រែងរបស់កូនៗដែលជាអ្នកស្រឡាញ់ភេទដូចគ្នាក្នុងការពន្យល់បកស្រាយនូវភាពលំបាក សេចក្តីត្រូវការ និងសារៈសំខាន់នៃដំណោះស្រាយឱ្យមានការទទួលស្គាល់ និងការការពារផ្នែកផ្លូវច្បាប់សម្រាប់គ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា។



ការចូលរួមរបស់លោកពូ តូ ចាប់ពីឆ្នាំ២០១៨ ជាសាក្សីនៅក្នុងការចុះសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ (កិច្ចសន្យាឯកជន) សម្រាប់កូនៗរបស់គាត់។ ការចូលរួមគាំទ្រយ៉ាងពេញទំហឹងរបស់លោកពូ តូ ក៏ដោយសារតែសេចក្តីក្លាហាន និងសេចក្តីព្យាយាមរបស់ស្មើនិងស្រីណុចដែលជាកូននិងកូនប្រសារ ក្នុងការពន្យល់សួរនាំ និងជំរុញលើកទឹកចិត្ត ដោយភាពអំណត់និងសេចក្តីគោរពចំពោះលោកពុកនិងអ្នកម្តាយ គ្រប់កម្មវិធីទាំងអស់។

## ៤.២. សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមានទំនុកចិត្ត ជំនឿជឿជាក់ និងមានទឹកចិត្តបន្តដំណើរការតស៊ូមតិដើម្បីសមភាពច្បាប់អាពាហ៍ពិពាហ៍




ស៊ន នឿនដែលជាសមាជិកសកម្មរ៉ក់ ដែលបានមើលឃើញការប្រារព្ធកម្មវិធីសិទ្ធិមនុស្សអន្តរជាតិ និងការជួបជជែកជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានតាំងពីឆ្នាំ២០០៩កន្លងមក យល់ថា គាត់អាចមើលឃើញពីសញ្ញាភ្លើងខៀវពីសំណាក់រាជរដ្ឋាភិបាលដែលជាដំណើរខិតទៅមុខម្តងបន្តិចៗហើយ ដែលផ្តល់នូវកំលាំងចិត្តដល់គាត់បន្ថែមទៀតក្នុងការចូលរួមតស៊ូមតិ។

ខ្ញុំទទួលយក

RUCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

## ៥. សាធារណជនចាប់ផ្តើមដឹងពីបញ្ហា និងតម្រូវការនៃសមភាពច្បាប់អាពាហ៍ពិពាហ៍ សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា ដែលកើតចេញពីការបន្ទសំឡេង ដែលអាចកើតឡើងដោយសារ៖

៥.១. សម្លេងគាំទ្រពីបណ្តាញសង្គមស៊ីវិលធ្វើការលើកកម្ពស់សិទ្ធិសុខភាពផ្លូវនិងបន្តពូជ សិទ្ធិស្ត្រី សមភាពយេនឌ័រ កុមារ អ្នកស្រឡាញ់ភេទដូចគ្នា សិល្បៈ និងវប្បធម៌ បានចូលរួមសហការ និងគាំទ្រការរៀបចំ កិច្ចសន្ទនា និងយុទ្ធនាការខ្ញុំទទួលយក-I Accept ។

៥.២. ការចូលរួមយកព័ត៌មាន បទយកការ និងសរសេរអត្ថបទផ្សព្វផ្សាយរបស់សារព័ត៌មាន ដែលរ៉ក់បានសហការជាមួយនិងស្ថាប័នដទៃទៀត បានបង្កើតនូវមាតិកានៃព្រឹត្តិការណ៍ អត្ថន័យខ្លឹមសារ និងគោលបំណងបានយ៉ាងត្រឹមត្រូវ ច្បាស់លាស់ និងវិជ្ជមានប្រកបដោយវិជ្ជាជីវៈ។

៥.៣. ក្រុមការងារធ្វើការលើបណ្តាញសង្គមមានលទ្ធភាពផ្សព្វផ្សាយបានច្រើន ទូលំទូលាយ និងទាន់ពេលពេលវេលាសម្រាប់ព្រឹត្តិការណ៍ដែលបានរៀបចំឡើង។

៥.៤. សមត្ថភាពក្រុមការងាររ៉ក់ក្នុងការសម្របសម្រួល កៀរគរធនធនជួយចូលរួមគាំទ្រ និងកិច្ចសហការជាលក្ខណៈបុគ្គល និងស្ថាប័ន មានភាពសកម្ម និងទទួលខុសត្រូវ។

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION



ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២១ នៅឧត្តមហ្គាដិន៖ កម្មវិធីសម្តែងនិងពិព័រណ៌សិល្បៈ
(កំណត់ការចូលរួមរបស់សាធារណជនចំនួន២៥០នាក់)




ខ្ញុំទទួលយក

RCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# បណ្ដាញសង្គម ដែលរ៉ក់ប្រើ

ហ្វេសប៊ុក

ធ្វីទទ័រ

គេហទំព័រវេបសាយ

# ទំព័រ ខ្ញុំទទួលយក







# ទំព័រ រ៉ក់



# ការចុះផ្សាយពីយុទ្ធនាការខ្ញុំទទួលយក

1. អត្ថបទផ្សព្វផ្សាយនៃទិវាសិទ្ធមនុស្សអន្តរជាតិ២០២១
2. សហគមន៍អ្នកស្រលាញ់ភេទដូចគ្នាចង់មានច្បាប់រៀបការ ខណៈប្រធានសិទ្ធិមនុស្សកម្ពុជាគាំទ្រ
3. យុទ្ធនាការ “ខ្ញុំទទួលយក” បំណងចង់ឱ្យមានសមភាពច្បាប់អាពិពាហ៍ពិពាហ៍អ្នកស្រលាញ់ភេទដូចគ្នា
4. ឯកឧត្តម កែវ រ៉េមី ៖ ខ្ញុំមិនទុកឱ្យអ្នកស្រលាញ់ភេទដូចគ្នារស់នៅឯកានោះទេ
5. LGBT+ Community Launches Marriage Campaign
6. សហគមន៍អ្នកស្រលាញ់ភេទដូចគ្នាចង់មានច្បាប់រៀបការ ខណៈប្រធានសិទ្ធិមនុស្សកម្ពុជាគាំទ្រ
7. មេសិទ្ធិមនុស្សកម្ពុជា ទទួលស្គាល់ថាសង្គមកម្ពុជា មានការរើសអើងការស្រឡាញ់ភេទដូចគ្នា ពីសំណាក់ក្រុមគ្រួសារ សហគម និង មនុស្សនៅជុំវិញខ្លួន
8. គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គាំទ្រឲ្យបង្កើតច្បាប់ធ្វើសំបុត្រអាពាហ៍ពិពាហ៍ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា
9. យុទ្ធនាការ «ខ្ញុំទទួលយក» ដើម្បីសមភាពច្បាប់រៀបការ ដល់អ្នកស្រឡាញ់ភេទដូចគ្នា
10. កិច្ចពិភាក្សាប្រចាំសប្តាហ៍៖ ស្ថានភាពបច្ចុប្បន្ន នៃអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា
11. ប្រធានបទ តើអ្នកស្រលាញ់ភេទដូចគ្នា អាចធ្វើអ្វីបានខ្លះ នាពេលបច្ចុប្បន្ននេះ ?
12. ទិវាសិទ្ធិមនុស្សអន្តរជាតិរបស់ស្រឡាញ់ភេទដូចគ្នា ២០២១
13. ទិវាសិទ្ធិមនុស្សអន្តរជាតិ “ខ្ញុំទទួលយក”
14. យុទ្ធការ« ខ្ញុំទទួលយក និងសមភាពច្បាប់អាពាហ៍ពិពាហ៍»

ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា RCK RAINBOW COMMUNITY KAMPUCHEA ORGANISATION


CCIM
DCA
ដុង ហេ · 11:19
Pou Oeun · 13:35
Nong Ly Heang Nong · 17:18
មានន័យថាឲ្យកម្ពុជាទទួលយកសិទ្ធិទាំងអស់នៃ
មនុស្សកុំប្រឆាំងសិទ្ធិមនុស្ស


KLEYKLEY.SABAY.COM.KH
គោះទៅមើល និងថតរូបជាមួយ ឥន្ទធនូ២០២១របស់សិល្បករសហសម័យខ្មែរ វុធ លីណូ


I accept
Published by Keodarika Darith · December 10 at 5:19 PM
#IAccept
#loveforall #happiness4all #LGBTIQ #equalmarriage #marriageequality
BTV
BTV Cambodia
December 10 at 10:44 AM
https://youtu.be/aHHRrrmwgPY
Join Telegram: https://t... See more


I accept
Published by Keodarika Darith · 1d
#Iaccept #Happiness4all #loveforall #LGBTIQ #equalmarriage

## ៦. សាមគ្គីភាព សុខដុមរមនីកម្ម និងការផ្សះផ្សាផ្លូវចិត្ត និងទំនាក់ទំនងរវាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ឪពុកម្តាយ អាជ្ញាធរមូលដ្ឋាន អាជ្ញាធរថ្នាក់ជាតិ និងសាធារណជន តាមរយៈ៖

- ពេលវេលា ដំណើរការ និងវិធីសាស្ត្រ ដែលច្បាស់លាស់ ជាប់លាប់ និងប្រចាំ ក្នុងការភ្ជាប់ទំនាក់ទំនង
- ឥរិយាបថ និងអាកប្បកិរិយាប្រកបដោយសីលធម៌ និងសុជីវធម៌
- ទីកន្លែងដែលមានសុវត្ថិភាព និងកក់ក្តៅ
- ទំនាក់ទំនង ភាពជឿទុកចិត្ត និងការយល់ចិត្តគ្នា
- ចំណេះដឹង និងព័ត៌មាន
- ភស្តុតាង និងបទពិសោធន៍
- សេចក្តីក្លាហាន និងជំនឿចិត្ត
- សំឡេងម្នាក់ និងរួម កំលាំងប្រមូលផ្តុំ ភាពអត់ធ្មត់ ស្និតស្នាញ និងសាមគ្គីភាព

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION



# យើងទាំងអស់គ្នារស់នៅក្នុងសង្គមតែមួយដែលមានសុខដុមរមនាកម្ម!

ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION